ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

សេចក្តីប្រកាសព័ត៌មាន

**លទ្ធផលនៃកិច្ចពិគ្រោះយោបល់ទ្វេភាគីលើកទី៣ រវាង**
**កម្ពុជា និង ស្វីស**
**ធ្វើនៅភ្នំពេញ ថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០២៣**

រាជធានីភ្នំពេញ ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៣ - នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៣ **ឯកឧត្តមបណ្ឌិត ចែម វីឌ្យា** រដ្ឋលេខាធិការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានធ្វើជាសហប្រធានដឹកនាំកិច្ចពិគ្រោះយោបល់នយោបាយទ្វេភាគីកម្ពុជា-ស្វីស លើកទី៣ ជាមួយ **ឯកឧត្តម ហៃនរីហ្ស ឆេលិនប៊ែខ** (Heinrich Schellenberg) រដ្ឋលេខាធិការទទួលបន្ទុកអាស៊ីប៉ាស៊ីហ្វិក នៃក្រសួងការបរទេសស្វីស នៅទីស្តីការក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។

ភាគីទាំងពីរបានកត់សម្គាល់ដោយការពេញចិត្តខ្ពស់ចំពោះចំណងមិត្តភាពដ៏ល្អប្រសើរជាប្រពៃណី និងកិច្ចសហប្រតិបត្តិការជិតស្និទ្ធ ដែលមានស្រាប់រវាងប្រទេសទាំងពីរ។ ភាគីទាំងពីរបានចែករំលែកអំពីទិដ្ឋភាពទូទៅនៃស្ថានភាពនយោបាយ និងសេដ្ឋកិច្ចនៅក្នុងប្រទេសរៀងៗខ្លួន ហើយបានបន្តពិភាក្សាអំពីទំនាក់ទំនងទ្វេភាគីដែលគ្របដណ្តប់លើផ្នែកនយោបាយ ការអភិវឌ្ឍ និងសេដ្ឋកិច្ច។ កិច្ចពិភាក្សាផ្តោតទៅលើវិស័យជាច្រើននៃកិច្ចសហប្រតិបត្តិការទ្វេភាគី រួមមានវិស័យសុខាភិបាល អភិបាលកិច្ច វិមជ្ឈការ កសិកម្ម សន្តិសុខអាហារ ពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការដោះមីន និងជំនួយអភិវឌ្ឍន៍ ព្រមទាំងកិច្ចសហប្រតិបត្តិការក្នុងអង្គការអន្តរជាតិ ដូចជា អង្គការសហប្រជាជាតិ និងកិច្ចសហប្រតិបត្តិការអាស៊ាន-ស្វីស។ល។ ភាគីទាំងពីរបានប្តេជ្ញាចិត្តរួមគ្នាយ៉ាងមុតមាំក្នុងការជំរុញកិច្ចសហប្រតិបត្តិលើវិស័យទាំងនោះ។ ភាគីទាំងពីក៏បានផ្លាស់ប្តូរទស្សនៈបន្ថែមទៀតអំពីបញ្ហាក្នុងតំបន់ និងអន្តរជាតិ ដែលជាចំណាប់អារម្មណ៍ និងកង្វល់រួម។

**ឯកឧត្តមបណ្ឌិត ចែម វីឌ្យា** បានថ្លែងនូវសេចក្តីអំណរគុណយ៉ាងជ្រាលជ្រៅរបស់ប្រជាជនកម្ពុជា ដល់ប្រទេសស្វីសចំពោះជំនួយអភិវឌ្ឍដ៏ថ្លៃថ្លាសម្រាប់កម្ពុជាក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ព្រមទាំង សាទរស្នាដៃការងារដ៏អស្ចារ្យរបស់**មន្ទីរពេទ្យគន្ធបុប្ផា** ចំពោះកុមារ និងស្ត្រីកម្ពុជា។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

**ឯកឧត្តម** Heinrich Schellenberg បានកោតសរសើរចំពោះវឌ្ឍនភាពសេដ្ឋកិច្ចដ៏ឆាប់រហ័សដែលកម្ពុជាសម្រេចបាន និងកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែងប្រកបដោយជោគជ័យរបស់កម្ពុជាក្នុងការទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩ និងបានបញ្ជាក់សាជាថ្មី អំពីការបន្តការគាំទ្ររបស់ប្រទេសស្វីសដល់**មន្ទីរពេទ្យគន្ធបុប្ផា** ក៏ដូចជា កម្មវិធីកិច្ចសហប្រតិបត្តិការថ្មីនៅក្នុងតំបន់មេគង្គឆ្នាំ២០២២-២០២៥។ **ឯកឧត្តម** Heinrich Schellenberg ក៏បានអបអរសាទរដល់កម្ពុជាចំពោះសមិទ្ធិផលដ៏អស្ចារ្យក្នុងនាមជាប្រធានអាស៊ាននៅឆ្នាំ២០២២ ដែលបានឆ្លុះបញ្ចាំងតាមរយៈតួនាទីយ៉ាងសកម្ម និង ការខិតខំប្រឹងប្រែង ប្រកបដោយជោគជ័យក្នុងនាមជាប្រធាន ដើម្បីកាត់បន្ថយភាពតានតឹងក្នុងតំបន់។

ក្នុងវិស័យពាណិជ្ជកម្ម និងវិនិយោគ **ឯកឧត្តមបណ្ឌិត ថៃម វីឡា** រដ្ឋលេខាធិការ បានកត់សម្គាល់ដោយក្តីពេញចិត្តចំពោះទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ដែលនៅតែបន្តកើនឡើងយ៉ាងឆាប់ ទោះបីជាមានការរីករាលនៃជំងឺកូវីដ-១៩ ក្នុងរយៈពេលបីឆ្នាំកន្លងមកយ៉ាងណាក៏ដោយ។ ដើម្បីបង្កើនទំហំពាណិជ្ជកម្មឱ្យកាន់តែប្រសើរឡើងថែមទៀត ឯកឧត្តមបណ្ឌិតរដ្ឋលេខាធិការ បានស្នើឱ្យមានការរៀបចំវេទិកាធុរកិច្ចរវាងសភាពាណិជ្ជកម្មនៃប្រទេសទាំងពីរ និងបន្តពិភាក្សាអំពីលទ្ធភាពបង្កើតឱ្យមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីផងដែរ។

កិច្ចពិគ្រោះយោបល់នយោបាយទ្វេភាគីរវាងក្រសួងការបរទេសទាំងពីរបានប្រព្រឹត្តទៅដោយជោគជ័យក្នុងបរិយាកាសស្និទ្ធស្នាល និងប្រកបដោយផ្លែផ្កា ដែលពោរពេញទៅដោយចំណងមិត្តភាពដ៏ល្អប្រសើរនៃទំនាក់ទំនងរវាងកម្ពុជា និងស្វីស។

លើសពីនេះទៀត ប្រទេសទាំងពីរបានរៀបចំកម្មវិធីសម្តែងរបាំវប្បធម៌ ដើម្បីអបអរសាទរ**ខួបលើកទី៦០ឆ្នាំនៃការបង្កើតទំនាក់ទំនងការទូតរវាងព្រះរាជាណាចក្រកម្ពុជា-ស្វីស** នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ៕